# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១២

## ជប៉ុនផ្តល់ ១០៨,៩០០ដុល្លារអាមេរិក សម្រាប់គម្រោង សាងសង់អាងស្តុកទឹកភ្លៀង ក្នុងស្រុកសង្កែ ខេត្តបាត់ដំបង

ក្រោមគ្រោងការជំនួយឥតសំណង សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុន នឹងផ្តល់ទឹកប្រាក់សរុបចំនួន ១០៨,៩០០ ដុល្លាអាមេរិកដល់ អង្គការស្តាបនាកម្ពុជា (CBO) ។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាដោយ ឯកឧត្តម ម៉ាសាហ៊្វូមី គូរ៉ូគី ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង លោក គុជ រូសាល ប្រធាន ប្រតិបត្តិ អង្គការស្តាបនាកម្ពុជា (CBO)។

ដើម្បីលើកស្ទួយស្ថានភាពសុខភាពកុមារ អង្គការស្តាបនាកម្ពុជា(CBO)នឹងសាងសង់អាងស្តុកទឹកភ្លៀង និង តំឡើងតម្រងទឹក ក្នុង សាលាបឋមសិក្សា១៦ ក្នុងស្រុក សង្កែ ខេត្ត បាត់ដំបង។ យើងរំពឹងថា គម្រោងនេះនឹងជួយបង្កើនគុណភាពទឹកពិសារ និង ផ្តល់អត្ថប្រយោជន៍ដល់លោកគ្រូ អ្នកគ្រូ និង សិស្សានុសិស្ស ជាង ៨,៧០០ នាក់។

កម្មវិធី ជំនួយឥតសំណង សម្រាប់គម្រោងទ្រង់ទ្រាយតូច សន្តិសុខមនុស្សជាតិ (*ជំនួយគូសាណូណិ*) របស់រដ្ឋាភិបាលជប៉ុន ដែលបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រសកម្មភាពរបស់អង្គការទាំងនេះ ក្នុងកិច្ចខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍន៍ និង ស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោង ជំនួយ នេះ មានទិសដៅ ការពារ ជនងាយរងគ្រោះ ពីកត្តា មួយចំនួន ដូចជា ភាព ក្រីក្រ និង ភាពអកុសល ដែលអាចគំរាមកំហែង ដោយផ្ទាល់ ដល់ជីវភាពរស់នៅ ការចិញ្ចឹម ជីវិត និង សេចក្តីថ្លៃថ្នូរ របស់ពួកគេ ក៏ដូចជាជួយជំរុញនូវ ភាពម្ចាស់ការ លើខ្លួនឯង របស់ ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកា ជាង៤៦.៥លានដុល្លាអាមេរិក ដល់អាជ្ញាធរមូលដ្ឋាន និង អង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន៤៦០គម្រោង នៅទូទាំងប្រទេស។

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ: ០២៣-២១៧-១៦១ ទូរសារ: ០២៣-២១៦-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*